Montreal,  le 9 Juin 2003

# ឱ ! ដែនដីកម្ពុជាក្រោមដ៏សែនស្រណោះ !

សូមជម្រាបមកលោក ថាច់ ស៊ីថា សមាជិកព្រឹទ្ធសភានៃរាជាណាចក្រកម្ពុជា នឹង ជាប្រធានសមាគមខ្មែរកម្ពុជាក្រោមនៅព្រះរាជាណាចក្រកម្ពុជាជាទីរាប់អាន ។

ខ្ញុំឈ្មោះ ខែម ខៀវ ជនជាតិខ្មែររស់នៅក្រុងម៉ុងរ៉េអាល់ប្រទេសកាណាដា សុំចូលរួបរួមក្នុងកម្មវិធីបុណ្យរំលឹកថ្ងៃបាត់បង់ទឹកដីកម្ពុជាក្រោមគម្រប់ឆ្នាំទី៥៤ នៅថ្ងៃទី៤ ខែមិថុនា ២០០៣ យ៉ាងក្រៀមក្រំជាទីបំផុតនឹកដល់ដែនដីកម្ពុជាក្រោមដ៏សែនស្រណោះរបស់ខ្មែរយើងទាំងអស់គ្នាដែលប្រទេសបារាំងបានសម្រេចប្រគល់ឲ្យទៅយួនកាន់កាប់តាំងពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ ១៩៤៩ Ratification de Rattachement de la République autonome de la Cochinchine(Kampuchea Krom) á l'Annam par le Président de la République francaise du 04 Juin 1949 .ដោយគ្មានការតវ៉ាពី ប្រទេសកម្ពុជា ឬ ពីព្រះមហាក្សត្រ ពោលគឺព្រះបាទ នរោត្តម សីហនុ សូម្បីតែមួយម៉ាត់ក៏គ្មានដែរ គួរឲ្យឈឺចាប់ណាស់បើខ្មែរទាំងអស់ដឹងពីព្រឹត្តិការដ៏សែនអាក្រក់ជាប្រវត្តិសាស្ត្រដែលស្តេចខ្មែរមិនបានការពារទឹកដីរបស់ខ្លួនបណ្តោយឲ្យបាត់ដីកើតមានឡើងនៅពេលនោះ។

លោក ថាច់ ស៊ីថា ជាទីរាប់អាន ! លោកមានប្រាជ្ញាវាងវៃល្អណាស់ លោកចេះរកមធ្យោបាយបញ្ចូលការបាត់បង់ទឹកដីកម្ពុជាក្រោមទៅក្នុងអារម្មណ៏កូនខ្មែរឲ្យចងចាំរស់រវើកឡើងវិញ ឲ្យដឹងថាកម្ពុជាក្រោមជាដែនដីរបស់ខ្មែរយើងត្រូវតែទាមទារពីយួនយកមកវិញឲ្យទាល់តែបាន។ ពិធីបុណ្យរំលឹកថ្ងៃបាត់បង់ទឹកដីកម្ពុជាក្រោមនេះ ជាសារមួយបញ្ជូនជាតំណឹងដល់សកលលោកទាំងមូលជាពិសេសដល់យួនឲ្យដឹងប្រាកដថា ដីយួនភាគខាងត្បូងសព្វថ្ងៃនេះជាដីរបស់ខ្មែរ ត្រូវតែយួនប្រគល់មកឲ្យប្រទេសខ្មែរមកវិញជាបន្ទាន់ ។ ឯប្រទេសបារាំងក៏ត្រូវតែលប់ចោលទុកជាមោឃ: នូវហត្ថលេខាដែលខ្លួនបានចុះលើអ្វីដែលខ្លួនបានប្រគល់ដែនដីកម្ពុជាឲ្យទៅយួនខុសនឹងច្បាប់អន្តរជាតិនោះជាបន្ទាន់ដែរ ។ តាំងពីថ្ងៃទី៤ មិថុនា ១៩៤៩ មកកូនខ្មែរទាំងអស់ នៅកម្ពុជាលើតែងតែពោលគ្រប់ៗមាត់ថា: កម្ពុជាក្រោមជាដីរបស់ខ្មែរ តែមិនដែលបានដឹងថាតើកម្ពុជាក្រោមបែរមុខទៅខាង ណាទេ? តើមាន ទំហំប៉ុន្មានគីឡូម៉ែត្រក្រឡា? តើមានប្រជាជនខ្មែររស់នៅប៉ុន្មាននាក់? តើមានខេត្តប៉ុន្មានខេត្ត? តើខេត្តទាំងអស់នោះឈ្មោះអ្វីខ្លះ? ពោលគឺអត់ដឹងទាំងអស់។ បើខ្មែរក្រោមមានទុក្ខវេទនាដោយយួនធ្វើបាបមិនដែលខ្មែរលើជួយឈឺឆ្អាលការពារផលប្រយោជន៏ខ្មែរក្រោមម្តងណាឡើយដូចយើងបានឃើញសព្វថ្ងៃ នេះជាពិសេសរាជរដ្ឋាភិបាលខ្មែរតែម្តងដែលមិនយកចិត្តទុកដាក់ការពារទឹកដីនឹងផលប្រយោជន៏ខ្មែរកម្ពុជាម្តងណាឡើយ។

មិនតែប៉ុណ្ណោះ ខ្មែរកម្ពុជាក្រោម ឡើងមករស់នៅកម្ពុជាលើ ភាគច្រើនត្រូវអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់តាំងពីក្រោមដល់លើធ្វើបាបចោទប្រប្រកាន់គ្រប់បែបយ៉ាង ចោទថាជាយួនក៏មាន។ រដ្ឋាភិបាលដែលមានឈ្មោះ សរ ខេង ខ្មែរយៀកមិញឬខ្មែរក្រហមខ្ញុំយួនមានដើមកំណើតនៅក្នុងខេត្តព្រៃវែងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មិនដែលទទួលស្គាល់ខ្មែរកម្ពុជាក្រោមថាជាដីខ្មែរម្តងណាឡើយ។ ទើបតែមកដល់ពេលថ្មីៗនេះទេ ដោយមានការកៀបសង្កត់ជាខ្លាំងពីសំណាក់មតិមហាជនទើបខ្មែរយៀកមិញរូបនេះ "អតីតមេចោរនៅស្រុកមេសាងក្នុងខេត្តព្រៃវែង ធ្លាប់លួចគោ-ក្របីខ្មែរយកទៅលក់ឲ្យយួន" បង្ខំចិត្តទទួលស្គាល់ខ្មែរកម្ពុជាក្រោម ជាខ្មែរពេញសិទ្ធិដូចខ្មែរទូទាំងប្រទេសកម្ពុជាដែរ។ តាមស្មានប្រហែលមានតែក្នុងក្រដាសទេមើលទៅ?

ខ្មែរយើងដែលជាអ្នកដឹកនាំប្រទេសតាំងពីជំនាន់មុនរហូតមកដល់សព្វថ្ងៃនេះ ទាំងពួជស្តេច ទាំងពួជរាស្ត្រ មិនដែលនឹកចង់រំដោះដែនដី កម្ពុជាក្រោមមកវិញម្តងណាឡើយ ទោះតាមមធ្យោបាយអហឹង្សាឬតាមច្បាប់អន្តរជាតិ ដោយបំភ្លេចដែនដីកម្ពុជាក្រោមនេះចោលតែម្តង។ ខ្មែរយើងតែងតែចោទទៅលើ ប្រទេសបារាំងថាជាអ្នកប្រគល់ទឹកដីនេះទៅឲ្យយួនដោយខុសនឹងច្បាប់អន្តរជាតិមិនដែលចោទសួររកមុខអ្នកទទួលខុសត្រូវដែលបណ្តោយឲ្យប្រទេសបារាំងធ្វើយ៉ាងដូច្នេះ។ ខ្មែរយើងទាំងអស់មិនឆ្ងល់ផងថា ហេតុអ្វីបានជាប្រទេសបារាំងតែងតែផ្តាច់ទឹកដីខ្មែរឲ្យទៅយួន? ហេតុអ្វីបានជាប្រទេសបារាំងមិនផ្តាច់ទឹកដីយួនមកឲ្យខ្មែរម្តងណាសោះ?ចម្លើយគឺថា: មកពីអ្នកដឹកនាំជាកំពូលមិនចេះការពារទឹកដីរបស់ខ្លួន មកពីអ្នកដឹកនាំខ្មែរមិនស្គាល់ភារកិច្ចមិនស្គាល់កាតព្វកិច្ចរបស់ខ្លួនឲ្យច្បាស់លាស់ មិនមានគំនិតស្នេហាជាតិ មិនមានគំនិតការពារ ទឹកដី មិនមានគំនិតការពារផលប្រយោជន៏ប្រជារាស្ត្រម្តងណាឡើយ ភស្តុតាងជាក់ស្តែងមានមកហើយគឺ: តើប្រទេសកម្ពុជាពីសតវត្សរ៏ទី១២ មានទំហំប៉ុណ្ណា? តើសព្វថ្ងៃនេះមានទំហំប៉ុណ្ណា?ប្រទេសកម្ពុជានឹងបាត់បង់ទឹកដីទៅអនាគតយ៉ាងខ្លីនេះថែមទៀត បើសិនជាខ្មែរទាំងក្នុងប្រទេសទាំងក្រៅប្រទេស បណ្តោយទុកឲ្យ សាដាច់ ហ៊ុនសែន នឹង បក្ខពួក ជាបរិវ៉ាអាយ៉ង យួនដឹកនាំប្រទេសតទៅទៀតដោយមិនគាស់រំលើងឲ្យអស់ពួកអាក្បាលយួនខ្លួនខ្មែរនេះឲ្យអស់ពីទឹកដីកម្ពុជាឲ្យទាន់ពេលវេលានោះទេ? ។

ក្នុងពេលថ្មីៗកន្លងទៅនេះ សាដាច់ ហ៊ុនសែន បានប្រកាសថា: បើខ្មែរណាហ៊ានទៅរំដោះដែនដីកម្ពុជាក្រោមខ្លួនវានឹងប្រគល់កាំភ្លើងឲ្យមួយដើមម្នាក់ៗ ហើយវានឹងធ្វើក្តាម្ឈូសទុកឲ្យម្នាក់មួយៗទុកដាក់ខ្មោចអ្នកស្នេហាជាតិទាំងអស់នោះ។នេះចំជាសម្តីព្រហើនកោងកាចអាពួជក្បាលយួនខ្លួនខ្មែរពិតប្រាកដមែន។

ចាប់តាំងពីឆ្នាំ ១៨៦៣ រហូតមកដល់ឆ្នាំ ១៩៤៩អាណានិគមបារាំងបានកាត់ទឹកដីខ្មែរបន្តបន្ទាប់ដូចខាងក្រោមនេះឲ្យទៅកូសាំងស៊ីន ឬ យួន :

- ពីថ្ងៃទី ២៥ មិថុនា ១៨៦៧ បារាំងបានផ្តាច់ដែនដីកម្ពុជាក្រោមពីប្រទេសកម្ពុជានៅក្នុងរាជ្យស្តេច នរោត្តម ។
- ឆ្នាំ ១៨៧០-១៨៧២ បារាំងបានកាត់ស្រុកតាំ តាជាត់ នឹង ដែនដីនៅចន្លោះទន្លេវៃគោខាងកើត នឹង ទន្លេវៃគោខាងលិចបញ្ចូលទៅកូសាំងស៊ីន ក្នុងរាជ្យស្តេច នរោត្តម ។

- ឆ្នាំ ១៨៨៣ បារាំងបានកាត់ខេត្តទន្លេរពៅនឹងខេត្តស្ទឹងត្រែងទៅឲ្យកូសាំងស៊ីន ក្រោយមកបានបញ្ចូលខេត្តទាំងពីរនេះទៅឲ្យប្រទេសលាវវិញ ក្រោយមកទៀតទើបកាត់ឲ្យមកប្រទេសកម្ពុជាវិញ ក្នុងរាជ្យស្តេច នរោត្តម ។
- ឆ្នាំ ១៨៩៣ បារាំងបានកាត់ភូមិឆ្នាមផ្ដៅ ស្រុកព្រាល ស្រុកបរនឹលដែលយួនប្រែមកថា: Cuu An, Tranh An, Minh-Ngal, Loc Ninh, Phuc Lé rattachés á la cochinchine sous le régne du roi Norodom. ក្នុងរាជ្យស្តេច នរោត្តម ។
- ថ្ងៃទី ២២ វិច្ឆិកា ១៩០៤ ដែនដីភាគខាងកើតខេត្តស្ទឹងត្រែង សព្វថ្ងៃឈ្មោះដាឡាក់ជាដែនដីខ្ពង់រាបខាងកើតខេត្តរតនះគីរីបារាំងបានប្រគល់ឲ្យកូសាំងស៊ីន ក្នុងរាជ្យស្តេច ស៊ីសុវត្ថិ ។
- ឆ្នាំ ១៩១៤ ខេត្តពាមបន្ទាយមាស នឹង កោះត្រល់ សព្វថ្ងៃយួនហៅថា: Ha Tien , Phu Quoc ត្រូវកាត់ឲ្យយួនក្នុងរាជ្យស្តេចស៊ីសុវត្ថិ ។

- ថ្ងៃទី ១២ មេសា ១៩៣២ ប្រធានាធិបតីប្រទេសបារាំងបានឲ្យសច្ចានុមតិ ប្រគល់ខ្ពង់រាបដាឡាក់ឲ្យទៅយួនជាស្ថាពរក្នុងរាជ្យស្តេច ស៊ីសុវត្ថិ មុនីវង្ស ។ appelé par les Annamites: Ban Mithuot du haut plateau Darlac.

- ថ្ងៃទី ៣១ មករា ១៩៣៩ ដោយមានការទាស់ទែងរវាងខ្មែរ នឹង យួន បារាំងបានប្រគល់ទៅឲ្យយួនត្រួតត្រាក្នុងរាជ្យស្តេច ស៊ីសុវត្ថិ មុនីវង្ស ។ Koh tral( Phu Quoc) est rattachée á la Cochinchine sous le régne du roi Sisowath Monivong “Direction des affaires politiques no- 367API. décrétée par le Gouverneur général de l’Indochine á Hanoi le 31 Janvier 1939 signée :Brévié. La limite de la frontiére maritime historique entre la Cochichine et le Cambodge est marquée par cette tracée ce qu’on appelle la ligne bréviée que le Vietnam actuel ne respecte pas .” ថ្ងៃទី ១ មិថុនា ១៩៤៦ គឺក្រោយសង្គ្រាមលោកលើកទី២ បារាំងបានប្រកាសដាក់ដែនដីកម្ពុជាក្រោមទៅជាសាធារណរដ្ឋស្វ័យយ័តកូសាំងស៊ីន (Kampuchea krom est proclamé en république autonome de la Cochinchine au sein de L’Indochine francaise dont pays membres: le Cambodge, l’Annam et le Laos ) **នៅក្នុងរាជ្យស្តេច នរោត្តម សីហនុ ។**

- ថ្ងៃទី ២៣ មេសា ១៩៤៨ អ្នកតំណាងរាស្ត្រសាធារណៈរដ្ឋស្វ័យយ័តកូសាំងស៊ីនដែលសុទ្ធតែជនជាតិយួនបានប្រកាសជាឯកច្ឆ័ន្ទដាក់ដែនដីកម្ពុជាក្រោមទៅនៅក្រោមអាណាព្យាបាលរបស់អាណ្ណាមឬយួន ។ Proclamation unanime de rattachement de la République autonome de la Cochinchine á l’Annam par des députés totalement annamites du 23 Avril 1948. នៅក្នុងរាជ្យស្តេច នរោត្តម សីហនុ ។

- ថ្ងៃទី ៤ មិថុនា ១៩៤៩ ក្រោយពីមួយឆ្នាំមក ដោយមិនឃើញស្តេចខ្មែរគឺព្រះបាទ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា មិនតវ៉ាជំទាស់នឹងសេចក្តីសម្រេចរបស់អ្នកតំណាងរាស្ត្រយួនដាក់ដែនដីកម្ពុជាក្រោមទៅនៅក្រោមអាណាព្យាបាលរបស់យួន។ ប្រធានាធិបតីប្រទេសបារាំងក៏សម្រេចធ្វើសច្ចានុម័តប្រគល់ដែនដីកម្ពុជាក្រោមឲ្យទៅយួនជាស្ថាពរតាំងពីពេលនោះមក គឺនៅក្នុងរាជ្យស្តេច នរោត្តម សីហនុ ។ Ratification de la Cochinchine(Kampuchea Krom) á l’Annam par le Président de la République de la France sans protestation ni de revendication de notre Sa Majesté le Grand Roi Norodom Sihanouk descendant de trés pur sang des Rois Warmans, batisseurs d’Angkor, soi-disant Pére de L’Indépendance du Cambodge. Etant le Grand Roi á cette époque, Norodom Sihanouk est le seul et le principal respon- Sable de la perte de notre terre ancestrale : Kampuchea Krom devant l’histoire du Royaume du Cambodge du 4 Juin 1949 .

ដូច្នេះចាប់តាំងពីឆ្នាំ ១៨៦៣ រហូតមកដល់ឆ្នាំ ១៩៥៥ មានស្តេចខ្មែរសោយរាជ្យគ្រប់គ្រងព្រះរាជាណាចក្រកម្ពុជាជំនួនបួនព្រះអង្គហើយគឺៈ ព្រះបាទនរោត្តម ព្រះបាទស៊ីសុវត្ថិ ព្រះបាទស៊ីសុវត្ថិ មុនីវង្ស នឹង ព្រះបាទនរោត្តម សីហនុ។ស្តេចទាំងបួនព្រះអង្គនេះ មិនបានការពារទឹកដីនៃព្រះរាជាណាចក្រកម្ពុជាមិនឲ្យបាត់បង់ឡើយ ទោះបីអាណានិគមបារាំងកាត់ទឹកដីឲ្យទៅយួន ឬ ឲ្យទៅលាវ ក៏ព្រះអង្គទាំងបួនព្រះអង្គមិនរវីរវល់នឹងការពារ ឬ ប្រឆាំងនឹងបារាំងម្តងណាឡើយភស្តុតាងពិតប្រាកដដូចបានបរិយាយខាងលើនេះស្រាប់ ។

កាលពីថ្ងៃ ទី១៥ ទី១៦ មិថុនា ១៩៥២ ព្រះបាទនរោត្តម សីហនុ ព្រះមហាក្សត្រដ៏មហិមានៃប្រជារាស្ត្រខ្មែរ បានរំលាយរដ្ឋសភា នឹង រាជរដ្ឋាភិបាល របស់គណបក្សប្រជាធិបតេយ្យហើយប្រមូលអំណាចទាំងអស់យកមកក្តាប់យ៉ាងណែនក្នុងព្រះហស្ថ ដោយបានបង្កើតរាជរដ្ឋាភិបាលផ្ទាល់ព្រហស្ថព្រះអង្គដ៏ខ្លាំងអស្ចារ្យមួយដែលគ្មានរដ្ឋសភាគាំទ្រឡើយ ។

ពេលនោះព្រះបាទ នរោត្តម សីហនុ ក៏ចាប់ផ្តើមទាមទាឯករាជ្យប្រទេសកម្ពុជាពីប្រទេសបារាំងមកវិញ ដោយបានប្រមូលកែនប្រជារាស្ត្រទូទាំងប្រទេសទាំងប្រុសទាំងស្រីចាប់ពីអាយុ១៨ឆ្នាំឡើងទៅ ឲ្យចូលធ្វើកងជីវពលបំពាក់ដោយកាំភ្លើងឈើគ្មានប្រហោងកាណុងនឹងគ្មានគ្រាប់ដើម្បីកំញើញបារាំងឲ្យរត់ចោលប្រទេសកម្ពុជា ។ កម្លាំងស្នេហាជាតិប្រកបដោយសម្លេងគងស្គរ សំភោរ ស្រឡៃ រនាតឯក រនាតធុង ។ល។ តាមកំដរក្បួនព្យុហយាត្រានៃកងជីវពលពេញទាំងផ្ទៃប្រទេសកម្ពុជាប្រៀបបានទៅនឹងសម្លេងខ្យល់ព្យុះកាច់បំបាក់កំពូលភ្នំឬទឹកធ្លាក់ពីកំពូលភ្នំ កងរំពងខ្ទរខ្ទាររបង្អើលមតិមហាជនអន្តរជាតិពេញ

សកលលោកទាំងមូល។ មហាយក្សទាំងពីរគឺៈ សហភាពសូវៀត នឹង សហរដ្ឋអាមេរិក ភ័យស្លន់ស្លោរឆ្វេឆ្វាប្រញ៉ាប់ប្រញ៉ាល់ស្រែកប្រកាសទទួលស្គាល់គាំទ្រជាផ្លូវការដល់ទង្វើរបស់ព្រះមហាក្សត្រយើង នូវអ្វីដែលព្រះមហាក្សត្រហៅថាទាមទាឯករាជ្យប្រទេសកម្ពុជាពីបារាំង ។ កងទ័ពបារាំងភ័យខ្លាចខ្លាំងណាស់នឹងកាំភ្លើងឈើស្វ័យប្រវត្តិ រត់យកតែព្រះអាយុទៅជ្រកពួនសម្ងំយកតែរស់ជីវិតនៅឯស្រុកយួនស្ងាត់ពីស្រុកខ្មែរ ប្រទេសបារាំងឃើញដូច្នោះភ័យរញ្ជីរញ្ជ័ស្ទើរលោះព្រលឹងប្រញាប់ប្រញាល់ មិនហ៊ានបង្អែបង្អង់ក៏ប្រគល់ឯករាជ្យដ៏បរិបូរណ៍នៃប្រទេសកម្ពុជា ថ្វាយព្រះបាទ នរោត្តម សីហនុ ព្រះមហាក្សត្រខ្មែរកាលពីថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ជាស្ថាពរ ។ ព្រះបាទ នរោត្តម សីហនុ ក៏បានតាំងព្រះហ័សនាមថាៈ ព្រះពិតាឯករាជ្យជាតិតាំងពីពេលនោះមក ។

លុះបានឯករាជ្យពេញបរិបូរណ៍ហើយពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ រហូតដល់ថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៥៥ សម្តេចនរោត្តម សីហនុ ទ្រង់គង់នៅជាព្រះមហាក្សត្រសោយរាជ្យ។ ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦០ រហូតដល់ថ្ងៃទី១៨ ខែមិនាឆ្នាំ១៩៧០ ព្រះអង្គទ្រង់គង់នៅជាប្រមុខរដ្ឋអស់មួយជីវិត ។ ក្នុងរជ្ជកាលចំនួន១៨ឆ្នាំនេះ ព្រះអង្គមានអំណាចខ្លាំងណាស់ចង់ធ្វើអ្វីក៏បានដែរ កិត្តិយស កិត្តិសព្ទល្បីសុះសាយពេញសកលលោក ។ ប្រទេសលោកខាងកើត លោកខាងលិចនឹងអង្គការសហប្រជាជាតិបានទទួលស្គាល់ប្រទេសកម្ពុជាជាសមាជិកនៅលើផ្ទៃរាបអន្តរៈជាតិ។ ហេតុអ្វីនៅក្រោយឆ្នាំ១៩៤៩នឹងឆ្នាំបន្តមកទៀតដែលទឹកខ្មៅបារាំងចុះហត្ថលេខាប្រគល់កម្ពុជាក្រោមឲ្យទៅយួនមិនទាន់ស្ងួតផងនោះ ម្តេចឡើយព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ មិនទាមទាទឹកដីកម្ពុជាក្រោមយកពីយួនមកវិញ ? ហេតុអ្វីព្រះអង្គទុកពេលវេលាឲ្យកន្លងផុតទៅឥតប្រយោជន៍ចំនួន៥៤ឆ្នាំ មិនទាមទាកេរ្តិ៍ដូនតាយើងមកវិញ ? តើមកពីមូលហេតុអ្វី ? មិនគ្រាន់តែមិនទាមទាទេ ព្រះអង្គប្រឆាំងនឹងគណៈប្រតិភូខ្មែរដែលបានទៅចចាជាមួយនឹងប្រទេសបារាំងឯក្រុងប៉ារិស ដោយបានផ្ញើទូរលេខ Télégramme បញ្ឈប់គណៈប្រតិភូនោះកុំឲ្យចចា ហើយឲ្យត្រឡប់មកស្រុកខ្មែរវិញជាបន្ទាន់ ។ តើខ្មែរយើងទាំងអស់គ្នានៅពេលបច្ចុប្បន្ននេះយល់ដូចម្តេចដែរចំពោះកាយវិការរបស់ព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ នៅពេលនោះ ? ស្នេហាជាតិ ឬ ក្បត់ជាតិ? ទើបតែមកដល់ពេលនេះ ខ្មែរកម្ពុជាក្រោមទ្រាំលែងបាននឹងការជិះជាន់ពីសំណាក់យួន បង្កើតសហពន្ធ័ខ្មែរកម្ពុជាក្រោមមួយដោយទទួលខុសត្រូវលើវាសនាខ្លួនដោយខ្លួនឯង រិះរកគ្រប់មធ្យោបាយដោយអហឹង្សាដើម្បីទាមទាទឹកដីកម្ពុជាក្រោមមកវិញ។ ឃើញដូច្នោះព្រះបាទនរោត្តម សីហនុ ព្រះមហាក្សត្រសោយរាជ្យលើកទីពីរ បក់ព្រះហស្ថឃ្វីចៗពីប៉េកាំងមកថាៈព្រះអង្គគាំទ្រគំរោងការនេះទាំងស្រុង ក៏ប៉ុន្តែសុំឲ្យសភាទាំងពីរ នឹង រាជរដ្ឋាភិបាលចុះហត្ថលេខាជាមុនសិនទើបព្រះអង្គអាចឡាយព្រះហស្តលេខាបាន ! ហាក់ដូចជាទើបនឹងតើនពីព្រះសុបិន្ត ! តើសាជាថ់ ហ៊ុនសែន យល់ដូចព្រះអង្គដែរឬទេ ? នេះជាព្រឹត្តិការណ៍បច្ចុប្បន្នរបស់ព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ ! គួរឲ្យអស់សំណើចណាស់ ! មេឃា ! ចាំមើល !

យើងងាកទៅក្រោយបន្តិចវិញ នៅទសវត្សរ៍ទី៦០ ពេលដែលយួនខាងត្បូង យួនយៀកកុង យួនខាងជើងច្បាំងកាប់ចាក់សម្លាប់គ្នា ដើម្បីដណ្តើមយកទឹកដីកម្ពុជាក្រោមដ៏សែនស្រណោះរបស់ខ្មែរយើងនោះ ព្រះប្រមុខរដ្ឋអស់មួយជីវិតដ៏មហិមាសម្តេចនរោត្តម សីហនុ មិនបានឆ្លៀតឱកាសដ៏ល្អនោះដើម្បីរកផលចំណេញទាមទាទឹកដីកម្ពុជាក្រោមពីគូភាគីទាំងពីរនោះឡើយ ។ តែព្រះប្រមុខរដ្ឋខ្មែរយើងដ៏ឆ្នើមតែមួយគត់លើលោកនេះ បែរជាទៅគាំទ្រយួនខាងជើងនឹងយួនយៀកកុងឲ្យច្បាំងឈ្នះដណ្តើមបានទឹកដីកម្ពុជាក្រោមពីឆ្នាំ១៩៧៥ ។ សម្តេចនរោត្តម សីហនុ អនុញ្ញាតឲ្យទ័ពយួនខាងជើងយួនយៀកកុងបោះទីតាំងទ័ពក្នុងដីខ្មែរតាមបណ្តោយព្រំប្រទល់ដែនយួនតាំងពីខេត្តរតនៈគីរី ខេត្តមណ្ឌល់គីរី ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តតាកែវ នឹង ខេត្តកំពត ។ ព្រះអង្គថែមទាំងបញ្ជាឲ្យកងខេមរភូមិនដឹកជញ្ជូនភសភាសម្ភារៈសឹកនឹងស្បៀងអាហារឲ្យទ័ពយួនកុម្មុយនិស្ត ធ្វើឲ្យប្រជារាស្ត្ររងទុក្ខវេទនាអត់បាយក្រហាយទឹក ។

La situation ne s’améliore pas dans les dix-huit mois qui suivent. Sihanouk passe aux actes. Le 25 novembre 1965, le général Lon Nol, chef d’état-major des Forces armées royales khméres(F.A.R.K.) se rend á Pékin sur son ordre et signe avec son homologue chinois, le général Lo Jui-ching un traité militaire qui stipule
Notamment :

1. Le Cambodge permettrait le passage et le refuge des combattants vietnamiens dans la région frontaliére, leur accorderait une protection si nécessaire et leur permettrait d’établir des postes de commandement.

2. Le Cambodge permettrait le passage de matériel destiné aux combattants vietnamiens en provenance de la Chine. (extrait du livre) “ LE MAL CAMBODGIEN “ de Marie Alexendrine Martin, page 100.

នេះហើយជាសមិទ្ធិរបស់ព្រះប្រមុខរដ្ឋ សម្តេចនរោត្តម សីហនុ ដើម្បីការពារទឹកដីខ្មែរ ក្នុងសម័យសង្គមរាស្ត្រនិយម. តើមកដល់ពេលនេះយួនកុម្មុយនិស្តសងគុណថ្វាយដល់ព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ ដល់កំរិតណាហើយ ?

L’ambition et l’incurie du Chef de l’Etat á vie Norodom Sihanouk avaient mené le Cambodge au bord de la Catastrophe ultime : la disparition de l’entité royale, politique et territoriale de notre bien-aimé “ LE CAMBODGE “.

ក្នុងការតស៊ូទាមទាទឹកដីកម្ពុជាក្រោមពីយួនមកវិញនេះ ខ្ញុំមានសេចក្តីសង្ឃឹមតែមួយគត់ទៅលើវីរៈភាពនៃខ្មែរកម្ពុជាក្រោមដែលជាម្ចាស់ស្រុកផ្ទាល់ ធ្លាប់រួមរស់សុខទុក្ខ រួមទទួលការធ្វើបាប ធ្វើទុក្ខបុកម្និញ ជិះជាន់រិបអូសដីស្រែចំការផ្ទះសំបែង ដុតវត្តអារាមផ្ទះសម្បែង ធ្វើគត់លោកសង្ឃ សម្លាប់ខ្មែរក្រោមរាប់សែននាក់ដូចជានៅក្នុងព្រឹត្តិការណ៏ ¨**ប្រយ័ត្នកំពប់តែអុង** ” ដែលស្តេចយួនឈ្មោះយ៉ាឡុង (Gia Long) នឹងស្តេចយួនឈ្មោះមិញម៉ាង (Minh Mang) ដោយមានមេទ័ពយួនឈ្មោះទ្រឿងមិញយ៉ាង (Truong Minh Giang) ជាអ្នកចាត់ចែងកែនខ្មែរកម្ពុជាក្រោមធ្វើជាទាសករ ឲ្យមកជីកព្រែកវិញតេហើយដុតសម្លាប់ទាំងរស់ ខ្លះទៀតត្រូវយួនចងដែចងជើងដាក់ក្នុងព្រែករួចបើកទឹកបញ្ជូលសម្លាប់គ្មានសល់ម្នាក់ឡើយ។ នេះជាឧក្រិតកម្មមួយក្នុងចំណោមអំពើសម្លាប់ខ្មែរក្រោមឲ្យផុតពូជជាច្រើនករណីទៀត។ យួនអាចប្រព្រឹត្តឧក្រិត្តកម្មនេះបានក៏ដោយសារការឲ្យដៃនៃស្តេចអង្គចាន់ ចន្លោះឆ្នាំ១៨១៣-១៨១៥ ។ Les rois Gia Long et Minh Mang de l’Annam avec la complicité du roi khmer Ang Chan, ordonnent aux Khmers de Kampuchea krom de creuser le canal de Vinh Té d’une longueur de 53 kilométres sur 25 métres de largeur dans le territoire de Peam Banteay Meas (Moath Chrouk). A ce moment le roi Ang Chan donne la faveur au général annamite nommé Truong Minh Giang en lui remettant l’épée martiale et le seau du trône afin de lui permettre de mobiliser des Khmers krom en corvée d’esclaves á entreprendre ces lourds travaux. Pour faire peur á ces pauvres Khmers krom de bien travailler,Truong Minh Giang avait enterré quelque Khmers en trio, en forme d’un triangle équilatéral jusqu’au cou servant de fourneau pour bouillir de l’eau afin de servir le thé aux Seigneurs annamites. Avant de mourir, sous l’action de la chaleur du feu, ces pauvres et innocentes victimes bougérent leur tête, Truong Minh Giang disait-il: “**ATTENTION ! NE BOUGER PAS ? VOUS FAITES DÉVERSER LE THÉ DU SEIGNEUR ANNAMITE ! “ en mi-langue cambodgienne-annamite ¨ ប្រយ័ត្នកំពប់តែអុង ¨ PRÂYATH** KÂMPOB THÉ ONG គួរឲ្យឈឺចាប់ខ្លោចផ្សារណាស់ប្រហែលជាខ្មែរភាគច្រើនមិនដឹងថាអ្វីទៅប្រយ័ត្នកំពប់តែអុងនោះទេ។ តាមការសង្កេតខ្មែរកម្ពុជាលើមិនសូវមានគំនិតតស៊ូដូចខ្មែរកម្ពុជាក្រោមទេ ជាពិសេសខ្មែរយៀកមិញ ខ្មែរក្រហមខ្ញុំយួនដឹកនាំរាជរដ្ឋាភិបាលសព្វថ្ងៃនេះគ្មានសុឆន្ទៈដោះស្រាយនូវរាល់អ្វីដែលយួនធ្វើបាបខ្មែរកម្ពុជាក្រោមនោះទេ! ឬគាំទ្រសហពន្ធខ្មែរកម្ពុជាក្រោមក្នុងការទាមទារសិទ្ធិសេរីភាពជូនខ្មែរកម្ពុជាក្រោមដែលរស់នៅលើទឹកដីរបស់ខ្លួនជាកេរ្តិ៍ដូនតានោះឡើយ។

ឯស្តេចខ្មែរវិញ តាំងពីក្រោយសម័យអង្គរមកមិនបានការពារទឹកដីឲ្យបានគង់វង់ទេ ដោយសារអង្គនិមួយៗចង់តែឡើងសោយរាជ្យអស់អ្វីក៏អស់ចុះឲ្យតែអង្គអញ់បានឡើងសោយរាជ្យ ។ La perte des territoires du Cambodge dans la passé

aurait été probablement et certaiement due á des querelles interminables des familles royales pour uniquement le trône. Dans le passé récent, le Cambodge, en proie á des guerres de succession de trône défendait mal ses frontiéres. Ainsi le Monarque régnant s'appuyait-il tantôt sur le Siam, tantôt sur l'Annam pour asseoir la légitimité de son pouvoir.

ឧទាហរណ៍ជាក់ស្តែងពិតប្រាកដ កាលពីទសវត្សរ៍ទី៦០ សម្តេចនរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋខ្មែរអស់មួយជីវិត មិនហ៊ានទាមទាទឹកដីកម្ពុជាក្រោមពីយួនខាងត្បូងទេ បែរជាទៅជួយច្បាំងយួនខាងជើងយកកម្ពុជាក្រោមឲ្យទៅយួនកុម្មុយនិស្ត ព្រោះព្រះអង្គត្រូវការពឹងយួនកម្មុយនិស្តឲ្យជួយការពារអំណាចរបស់ព្រះអង្គ ទោះបាត់បង់ទឹកដីអស់រលីងនៅសល់តែប៉ុនរាំង របស់ព្រះអង្គឬប៉ុនវត្តលោកសង្ឃក៏សម្តេចនរោត្តម សីហនុ សុខចិត្តយល់ព្រមដែរឲ្យតែបាននៅជាប្រមុខរដ្ឋអស់មួយជីវិតជារៀងរហូតទៅ ព្រោះព្រះអង្គឈ្វេងយល់ថា ខ្មែរក្រហមដែលចិនកុម្មុយនិស្តនឹងយួនកុម្មុយនិស្តនៅពីក្រោយជាសត្រូវស្លាប់រស់ ដូច្នេះព្រះអង្គត្រូវតែបង្ខំព្រះទ័យជួយគាំទ្រការពារផលប្រយោជន៍យួនកុម្មុយនិស្ត ដើម្បីឲ្យយួនសម្លាប់ឬរំលាយខ្មែរក្រហមជាស្ថ័យប្រវត្តិទៅវាចប់រឿងអេវំ ។ នេះជាព្រះរាជតំរេះដ៏ភ្លឺស្វាងរបស់សម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋអមតៈនៃព្រះរាជាណាចក្រកម្ពុជានៃដែនដីសុវណ្ណភូមិដែលមានប្រាសាទសីលាជាភស្តុតាងនោះ ។ ទង្វើនេះមិនខុសពីទង្វើរបស់សម្តេចក្រុមព្រះនរោត្តម រណ្ណឫទ្ធឡើយ។សម្តេចក្រុមព្រះនរោត្តម រណឫទ្ធសុខចិត្តធ្វើអ្វីក៏ធ្វើដែរឲ្យតែសាជាច់ ហ៊ុនសែនទុកឲ្យរស់ដូចកង្កែបដែលពស់សម្លាប់កង្កែបវាមិនទាន់លេបដោយសារវាមិនទាន់ឃ្លាន ព្រោះនៅស្រុកបារាំងធ្វើជាគ្រូបង្រៀនមិនមានមុខមាត់ទេម្ល៉ោះហើយត្រូវតែបង្ខំតាំងខ្លួនឲ្យទៅជាអ្នកនយោបាយគ្មានឧត្តមគតិទៅតាមយថាហេតុនៅជាខ្ញុំក្រោមខ្មែរអាយ៉ងយួនទៅចុះ។ ឯសាជាច់ ហ៊ុនសែនវិញក៏ត្រូវតែសម្របសម្រួលនយោបាយរបស់វាឲ្យស្របនឹងបំណងយួនដែរ ព្រោះយួនលើកឲ្យវាឈរត្រង់បាននៅលើប្រទេសកម្ពុជាក៏ដោយសារយួនយកដែកច្រនួចអាណានិគមដោតតាមបណ្តោយឆ្អឹងខ្នងឲ្យវា ទើបវាឈរត្រង់បានបើយួនដកដែកច្រនួចនោះចេញវាស្លាប់ហើយ ។ មតិខ្មែរមិនជឿថាអ្នកខាងលើនេះចង់ទាមទាទឹកដីកម្ពុជាក្រោមមកវិញទេ!

ដូច្នេះមានតែខ្មែរកម្ពុជាក្រោមទេ ដែលមានសហពន្ធខ្មែរកម្ពុជាក្រោម នឹង សមាគមខ្មែរកម្ពុជាក្រោម អាចដឹកនាំការទាមទារសិទ្ធិសេរីភាពជូនដល់ខ្មែរកម្ពុជាក្រោម នឹង រំដោះទឹកដីកម្ពុជាក្រោមឲ្យបានសម្រេចដូចបំណងមិនខានឡើយ ៕

**ខែម ខៀវ**

អតីតមន្ត្រីរាជការ ក្នុងសម័យសង្គមរាស្ត្រនិយម - អតីតមន្ត្រីរដ្ឋការ ក្នុងសម័យសាធារណៈខ្មែ

# ការបាត់បង់ទឹកដីនៃប្រទេសកម្ពុជា

កាលពីថ្ងៃទី១១ ធ្នូ ២០០៣ ព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សីហនុ បានប្រកាសក្នុងលិខិតឆ្លើយតបទៅនឹងលិខិតលោកថាច់ ស៊ីថា សមាជិកព្រឹទ្ធិសភាថាៈ"មិនដែលប្រគល់ទឹកដីនៃមាតុភូមិកម្ពុជាសូម្បីតែមួយចំអាមជូនទៅវៀតណាម ឬថៃ ឬឡាវនោះទេ ។ នៅក្នុងសម័យណាក៏ដោយ ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសឡាវ មិនដែលមានគុណអ្វីមកលើរាជាណាចក្រកម្ពុជា ហើយមហាក្សត្រខ្មែរ នឹង នរោត្តម សីហនុ មិនដែលក្បត់ជាតិ ប្រជារាស្ត្រ មាតុភូមិកម្ពុជាម្តងណាឡើយ ។"

បើយើងទាំងអស់គ្នាជាខ្មែរមិនបានដឹងពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាពីអតីតកាលមកយើងជាខ្មែរនឹងយល់ហើយស្តាប់ឮយ៉ាងពីរោះថាចម្រៀងរបស់ព្រះបាទនរោត្តម សហនុ ព្រះមហាក្សត្រខ្មែរពីប្រទេសកម្ពុជាដែលព្រះអង្គបានមានព្រះរាជឱង្ការថាមិនដែលឲ្យដីទៅយួនសូម្បីតែមួយចំអាមក៏គ្មានដែរ ហើយមិនដែលក្បត់ជាតិប្រជារាស្ត្រមាតុភូមិកម្ពុជាម្តងណាឡើយ ។ នេះជាការពិត! ព្រះអង្គគ្រាន់តែអនុញ្ញាតឲ្យយួនកុម្មុយនិស្ត នឹងយួនយៀកកុងលុកលុយតាមព្រំដែននៃប្រទេសខ្មែរយើងធ្វើជាទីតាំងទ័ពរបស់វាតាំងពីខេត្តរត្នគីរីរហូតដល់ខេត្តកំពត តាមរយៈសិទ្ធិសញ្ញាសម្ងាត់សែនមហាសម្ងាត់មួយដែលសម្តេចនរោត្តម សីហនុ មិនបានផ្សាយជាសាធារណៈឲ្យប្រជារាស្ត្រខ្មែរដែលជាម្ចាស់ប្រទេសកម្ពុជាបានដឹងឡើយតាំងពីឆ្នាំ១៩៦៥រហូតមកដល់សព្វថ្ងៃនេះ ។ កាលនោះសម្តេចនរោត្តម សីហនុ បានបញ្ជាឲ្យលោកឧត្តមសេនីយលន់ ណុល ទៅក្រុងប៉េកាំងចុះហត្ថលេខាលើសិទ្ធិសញ្ញាសម្ងាត់មួយជាមួយឧត្តមសេនីយចិនម្នាក់ដើម្បីអនុញ្ញាតឲ្យទ័ពយួនកុម្មុយនិស្ត នឹងយួនយៀកកុង នាំភ្លើងសង្គ្រាមមកដុតផ្ទះខ្មែរជាថ្នូរនឹងការធានារបស់យួនដែលយួនសុខចិត្តការពារព្រះអង្គសម្តេចឱឲ្យគង់ប្រថាប់នៅជាព្រះអគ្គមគ្គុទេសន៏ដ៏ឆ្នើមមានតែមួយគត់លើពិភពលោកនេះជាព្រះប្រមុខរដ្ឋអស់មួយជីវិត។ សិទ្ធិសញ្ញាសម្ងាត់នេះបានចុះហត្ថលេខាពីថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៦៥។ សូមអានសៀវភៅឯកសារមានឈ្មោះថា :<< LE MAL CAMBODGIEN >> de Marie Alexendrine Martin, page 100. ។ សម្តេចឱធ្វើយ៉ាងដូច្នេះព្រោះនៅក្រោមការឃោសនាបញ្ចុះបញ្ចូលរបស់ចិននឹងយួនកុម្មុយនិស្ត ព្រះអង្គយល់ឃើញថាមានតែចិនកុម្មុយនិស្តដែលត្រួតត្រាទ្វីបអាស៊ីទៅអនាគតដូច្នេះព្រះអង្គឈ្មុះៗៗៗរហូត ។ ដោយព្រះបាទនរោត្តម សីហនុ អនុញ្ញាតឲ្យយួនមកដុត

ផ្ទះខ្មែរយ៉ាងដូច្នេះ ព្រះអង្គក៏បានពង្រីកហើយពង្រឹងសង្គមរាស្ត្រនិយមរបស់ព្រះអង្គឲ្យក្លាយទៅជា "សង្គមរាស្ត្រយំ" ធ្វើឲ្យរាស្ត្រខ្មែររងទុក្ខវេទនា ប្រទេសកម្ពុជាហៀបតែនឹងរលាយពីផែនទីពិភពលោក រហូតមកដល់សព្វថ្ងៃនេះ ។

ទឹកដីតាមបណ្តោយព្រំដែនតាំងពីខេត្តរត្នគិរីរហូតដល់ខេត្តកំពតដែលសម្តេចឱ នរោត្តម សីហនុ អនុញ្ញាតឲ្យយួនកុម្មុយនិស្តបោះទីតាំងទ័ពនោះ យួនយករហូតមកដល់សព្វថ្ងៃនេះ ដោយសាដាច់ ហ៊ុន សែន បានប្រគល់ទឹកដីទាំងនោះទៅឲ្យយួនតាមសិទ្ធិសញ្ញាឆ្នាំ ១៩៧៩-១៩៨២-១៩៨៣-១៩៨៥ មិនអាចប្រកែកបានឡើយ ។ ហេតុដូច្នេះហើយបានជាយួនហ៊ានប្រកាសក្នុងពេលថ្មីៗនេះថាប្រទេសកម្ពុជាមានផ្ទៃក្រឡាចំនួនៈមួយសែនប្រាំពីរម៉ឺនប្រាំមួយពាន់ប្រាំរយម្ភៃគីឡូម៉ែត្រការ៉េ-"១៧៦.៥២០គីឡូម៉ែត្រការ៉េ"។ ការបាត់បង់ទឹកដីនេះមិនបានបូកបញ្ចូលទៅលើការបាត់បង់ទឹកដីកម្ពុជាក្រោមទាំងមូលផង ដែលប្រទេសបារាំងបានប្រគល់ឲ្យទៅយួនពីថ្ងៃទី ០៤ ខែ មិថុនា ១៩៤៩ ក្នុងរាជ្យព្រះបាទនរោត្តម សីហនុ ពេលនោះព្រះមហាក្សត្រខ្មែរយើងមិនបានតវ៉ាជាមួយបារាំងសូម្បីតែមួយម៉ាត់ក៏គ្មានដែរ

ចំណែកឯ ហ៊ុន សែន វិញតាំងតែពីយួនលើកបន្តុប នឹងក្រោយពីសម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃរដ្ឋកម្ពុជាបានតែងតាំងឲ្យឡើងងារជា សាដាច់ ហ៊ុន សែន មកក៏បានប្រកាសដូចព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ ដែរថាៈ ខ្លួនមិនដែលបានប្រគល់ដីខ្មែរឲ្យទៅយួន ឬទៅសៀម ឬទៅលាវ សូម្បីតែមួយចំអាមក៏គ្មានដែរ ហើយមិនដែលក្បត់ជាតិម្តងណាឡើយ ។ នេះសរឲ្យឃើញថាៈមួយដំបរស្មើនឹងបួនមែន ចុះវរជនណាដែលធ្វើឲ្យបាត់បង់ទឹកដីខ្មែរ ?សូមខ្មែរទាំងក្នុងប្រទេស ទាំងក្រៅប្រទេសពិចារណារកចម្លើយទៅតាមការយល់ឃើញម្នាក់ៗទៅចុះ ! ។ សាដាច់ ហ៊ុន សែន មានគុណមកលើខ្មែរខ្លាំងណាស់ មិនបានប្រគល់ដីឲ្យទៅយួនទេ តែធ្វើឲ្យយួនប្រគល់ដីយួនមកឲ្យខ្មែរវិញ (sic)អស្ចារ្យមែនដូចព្រះមហាក្សត្របានប្រកាសកាលពីថ្ងៃ ទី០៦ ខែធ្នូ ២០០៣ មុននេះ ។

ព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ បានមានព្រះរាជបន្ទូលថាមិនបានធ្វើឲ្យបាត់ដីសូម្បីតែមួយចំអាមក៏គ្មានដែរ នៅក្នុងរបបសង្គមរាស្ត្រនិយម ។ ឯសាដាច់ ហ៊ុន សែន វិញបាននិយាយថា បានធ្វើឲ្យប្រទេសខ្មែរចំណេញដោយបានធ្វើឲ្យយួនប្រគល់ភូមិយួនខ្លះៗនៅតាមបណ្តោយព្រំដែនមកប្រទេសខ្មែរ (sic) ។ ចុះហេតុអ្វីបានជាខ្មែរទាំងក្នុងទាំងក្រៅប្រទេសតែងតែចោទប្រកាន់ទៅលើអ្នកដឹកនាំប្រទេសកម្ពុជាទាំងអស់តាំងពីសម័យសង្គមរាស្ត្រនិ

យមមកថា: អ្នកទាំងអស់នោះបានធ្វើឲ្យបាត់បង់ទឹកដីបន្ថែមម្នាក់បន្តិចៗរហូតមកដល់សព្វថ្ងៃនេះ? ។ ពីអតីតកាលមក បើមានអ្នកដឹកនាំប្រទេសកម្ពុជា ដូចព្រះអង្គ នឹងប្រអង់ ទាំងពីរនេះប្រហែលប្រទេសកម្ពុជាមិនរួញមកនូវទំហំប៉ុនសព្វថ្ងៃនេះទេ ! ។ តែបើមានអ្នកដឹកនាំប្រទេសកម្ពុជាជំនាន់ក្រោយទៅអនាគត មានស្មារតីប្រហែលព្រះអង្គនឹងប្រអង់ទាំងពីរខាងលើនេះ ប្រទេសកម្ពុជានឹងរលាយពីផែនទីពិភពលោកដូចប្រទេសចំប៉ាកាលពីឆ្នាំ១៤០០ មិនខានឡើយ ។

សូមបញ្ជាក់ថាទឹកដីកម្ពុជាផ្នែកខាងកើតត្រូវបានយួនដណ្តើមយកបានបន្តរបន្ទាប់គ្នាដូចខាងក្រោមនេះ :

ខេត្តកំពង់ស្រកាត្រី នឹង ខេត្តព្រះសួគ៌ា (Bien Hoa et Baria ) : Année 1651
ខេត្តកំពង់គូ នឹង ខេត្តឈើទាលមួយ (Long An et Thu Dau Mot) : Année 1669
ខេត្តវាលប្រើស នឹង ខេត្តព្រៃនគរ (Don Nai et Saigon ) : Année 1696
ខេត្តក្រមួនសរ នឹង ខេត្តព្រែកឫស្សី (Rach Gia et Can Tho ) : Année 1716
ខេត្តពាមបន្ទាយមាស នឹង កោះត្រល់ (Hatien et Phu Quoc ) : Année 1722
ខេត្តមេសរ នឹង ខេត្តដំបូកកោង (My Tho et Go Cong ) : Année 1731
ខេត្តកំពង់ឫស្សី នឹងខេត្តឡុងហូ (Ben Trê etVinh Long ) : Année 1732
ខេត្តឃ្លាំង នឹង ខេត្តព្រះត្រពាំង (Soc Trang et Tra Vinh ) : Année 1734
ខេត្តផ្សារដែក នឹង ខេត្តមាត់ជ្រូក (Sa Dec et Chau Doc ) : Année 1748

នៅថ្ងៃ ទី២៥ ខែមិថុនា ១៨៦៧ អាណានិគមបារាំងបានកាត់ទឹកដីកម្ពុជាក្រោមដែលមានប្រជាជនខ្មែរកម្ពុជាក្រោមប្រហែល៤លាននាក់ "៤ ០០០ ០០០ នាក់" ពីប្រទេសកម្ពុជាយកទៅត្រួតត្រាផ្ទាល់ជាកម្មសិទ្ធិរបស់ប្រទេសបារាំង ។

Le traité du 25 juin 1867 mettant Kampuchea krom avec quattre millions de Khmers Kampuchea krom sur une superficie de 65.000 kilométres carrés, réparti en 23 Provinces : Kampong srâkar Trey, Preah Suokear, Prey Nokor, Kampong Kou, Raung Damrey, Prasat Pram Lovéng, Mé Sar, Kampong Russey, Morth Chrouk, Phsar Dék, Long Ho, Prek Russey, Preah Trâpeang, Khleang, Koh Trâlach, Pol Leav, Tuk Khmav, Krâmuon Sâr, Peam Banteay Meas, Chhoeu Teal Muoy, Veal Preus, Dambauk Kaung et Koh Trâl sous l’administration française qui devient la concession française ou la Cochinchine française ./

Montrèal, le 12 dècembre 2003
NOKOREACH